## តើអ្នកណាអាចជួយខ្ញុំបាន?

បើអ្នកមានសំនួរចង់ឲ្យគេជួយសុំសាកសួរអ្នកអេនូមេរិយធរដែល ដើរចែកនិងប្រមូលសន្ទឹកសិនសឹសដល់ផ្ទះអ្នក។

ម៉្យាងទៀតអ្នកអាចទូរស័ព្ទទៅសិនសឹសខ្សែជំនួយដោយឥតគិតថ្លៃ។ លេខទូរស័ព្ទនេះនឹងបើកធ្វើការពីថ្ងៃ១៩ ខែកុម្ភៈ ២០០១ទៅ។

លេខទូរស័ព្ទនេះគឺ **០៨០០-៨០-២០០១។**

## ជនបរទេសដែលមករស់នៅក្នុងប្រទេសញូស៊ីឡែន

បើអ្នកមិនចេះបំពេញសន្ទឹកនេះ គេអាចជួយអ្នកបាន។ អ្នកអាចពឹងមិត្តភ័ក្ដិឲ្យជួយ ឬទូរស័ព្ទទៅលេខ ០៨០០-៨០-១៩៩៦ សំរាប់ផ្ដល់អ្នកបកប្រែភាសាឲ្យ គេនឹងជួយអ្នកភ្លាម។

សេវកម្មបកប្រែមានផ្ដល់ជូនជាភាសា :

- ម៉េអរី
- សាមន
- ថុងងាន់
- កូរ៉េ
- ចិនមែនដារិន
- ចិនកន់តាំង

## ខ្សែទូរស័ព្ទសិនសឹសសំរាប់ជួយដោយឥតគិតថ្លៃ

អ្នកអាចទូរស័ព្ទទៅកន្លែងជំនួយសិនសឹសពី ទីណាក៏បានដែរនៅក្នុងប្រទេសញូស៊ីឡែននេះ ដោយឥតអស់ថ្លៃអ្វីឡើយ។

ចូរទូរស័ព្ទ

**០៨០០-៨០-២០០១**

ចាប់ពីថ្ងៃទី១៩ កុម្ភៈ ២០០១ទៅ។

**www.stats.govt.nz**

Statistics New Zealand
Te Tari Tatau

Census Tatauranga

Tautokotia, kei mahue koe. Make sure you count.

# ទាំងនេះគឺស្ដីអំពី សិនសឹស ២០០១

ទី៦មិនា២០០១

Statistics New Zealand
Te Tari Tatau

KHMER

## អ្វីទៅដែលហៅថាសិនសឹស?

សិនសឹសគឺការរាប់ជាផ្លូវការនូវចំនួនប្រជាជននិងផ្ទះទាំងអស់នៅក្នុងប្រទេសយើង។ ម្នាក់ៗត្រូវបំពេញសន្លឹកសិនសឹសម្នាក់មួយគ្រប់គ្នាទាំងអស់ក្នុងប្រទេសញូស៊ីឡែន។ ឪពុកម្ដាយត្រូវជួយបំពេញសន្លឹកឲ្យកូនម្នាក់មួយគ្រប់គ្នា ទោះជាទារកទើបនឹងកើតក៏បំពេញមួយដែរ។ សំនួរសួរមានច្រើនបែបណាស់ ប្ញករួមទាំងអាយុ សញ្ជាតិ អាជីវកម្មនិងសញ្ញាប័ត្រជាដើម។

ផ្ទះនិមួយៗក៏ត្រូវបំពេញសន្លឹកទីលំនៅហៅ Dwelling Form ឲ្យគេដែរ ដោយឲ្យសមាជិកតែម្នាក់ក្នុងផ្ទះបំពេញសន្លឹកនេះ។

## តើសិនសឹសលើកក្រោយក្នុងប្រទេសញូស៊ីឡែនធ្វើនៅពេលណា?

សិនសឹសលើកក្រោយខាងប្រជាជននិងលំនៅ នឹងធ្វើនៅថ្ងៃទី៦មិនា ២០០១។

## ហេតុអ្វីបានជាមានសិនសឹស?

នៅប្រទេសញូស៊ីឡែនសិនសឹសធ្វើ៥ឆ្នាំម្ដង នេះជាការដម្រូវរបស់ច្បាប់ក្នុងស្ថិតិក្រម ១៩៧៥ (Statistics Act 1975)។

ជាការសំខាន់ជាទីបំផុតដែលត្រូវប្រមូលពិតមានឲ្យបានត្រឹមត្រូវច្បាស់លាស់។ ពិតមាននេះយកទៅប្រើជាគ្រឹះសំរាប់គ្រោងអនាគតក្នុងសង្គមយើង។

## តើពិតមានសិនសឹសសំរាប់ប្រើធ្វើអ្វី?

ស្ថិតិអំពីប្រជាជនទូទៅ (មិនមែនពិតមានផ្ទាល់ខ្លួនម្នាក់ៗទេ) គេយកទៅប្រើក្នុងរដ្ឋាភិបាល ពានិជ្ជកម្ម រដ្ឋការដំបន់និមួយៗ ក្រុមសមាគម សាលារៀននិងផ្ទាល់ខ្លួន ដើម្បីប៉ាន់ស្មានសេចក្ដីត្រូវការនិងគ្រោងកិច្ចការទៅអនាគត។ ឧទាហរណ៍មួយដូចជា: សិនសឹសបង្ហាញថាក្នុងដំបន់នេះត្រូវការសាលារៀនថ្មីមួយ ព្រោះពិតមានក្នុងសិនសឹសប្រាប់ថាមានគ្រួសារដែលមានកូនតូចៗច្រើនណាស់បានរើផ្ទះមកនៅក្នុងដំបន់នេះ។

## តើសិនសឹសទាក់ទងអ្វីដល់អ្នក?

បើសិនជាជនម្នាក់ៗផ្ដល់នូវពិតមានប្រាកដនោះ ការសម្រេចដោះស្រាយអំពីសេវកម្មជាតិនិងតាមដំបន់យ៉ាងសំខាន់ដូចជាកន្លែងសង់ផ្លូវ ហាងលក់ដូរ មន្ទីសុខាភិបាលនិងសាលាជាដើមនោះ នឹងអាចធ្វើទៅបាន។ ក្នុងអំឡុងពេលជាងប្រាំឆ្នាំ ចំនួនប្រជាជននិងសេចក្ដីត្រូវការរបស់គេមានការផ្លាស់ប្ដូរណាស់។ ពិតមាននេះបង្ហាញឲ្យឃើញនូវអ្វីៗដែលបានផ្លាស់ប្ដូរនោះ។

ពិតមានពីសិនសឹសជួយអ្នកធ្វើគម្រោងការណ៍ឲ្យសំរេចសេចក្ដីថាតើប្រាក់ពីរដ្ឋការចំនួនប៉ុន្មានដែលត្រូវការយកមកជួយខាងសង់ផ្ទះសម្បែង កម្មវិធីជំនួយផ្សេងៗ ខាងជួយបង្ហាត់បង្រៀនឲ្យធ្វើការនិងប្រជាជនថ្មីដែលមករស់នៅក្នុងប្រទេស ដូចជាផ្ដល់ថ្នាក់រៀនភាសាអង់គ្លេសជាដើម។

## ពិតមានផ្ទាល់ខ្លួនដែលអ្នកផ្ដល់ឲ្យទាំងប៉ុន្មាននឹងទុនជាការសំងាត់?

តាមច្បាប់ អ្នកធ្វើការនៅក្រសួងស្ថិតិញូស៊ីឡែន (Statistics New Zealand) ត្រូវទុកពិតមានរបស់អ្នកជាការសំងាត់។ គ្មានជនណាអង្គការណាឬក្រសួងរដ្ឋណាផ្សេងៗទៀតអាចយកពិតមានពីសិនសឹសស្ដីអំពីជនណាម្នាក់បានឡើយ។

នេះគឺរាប់បញ្ចូលទាំងក្រសួងផ្ដល់កិច្ចការនិងថវិការ ក្រសួងពន្ធដារក្រសួងផ្ដល់ជំនួយពេលមានគ្រោះថ្នាក់ ក្រសួងប៉ូលិសនិងក្រសួងសេវកម្មអន្តោប្រវេសន៍ញូស៊ីឡែន។

ស្ថិតិញូស៊ីឡែនសួរឈ្មោះនិងអាស័យដ្ឋានដើម្បីបញ្ជាក់ឲ្យច្បាស់ថាសន្លឹកដែលគេដើរប្រមូលពីលំនៅនិមួយៗមានគ្រប់ចំនួនត្រឹមត្រូវដើម្បីឲ្យដឹងច្បាស់ចំនួនមនុស្សដែលរស់នៅជាមួយគ្នាក្នុងគ្រួសារនិមួយៗ ហើយត្រូវជាប់សាច់ញាត្តិយ៉ាងម៉េចជាមួយគ្រួសារនោះឬគ្រាន់តែជាមិត្តភ័ក្ដិរស់នៅជាមួយ។

## តើសិនសឹសធ្វើការយ៉ាងម៉េច?

សន្លឹកសិនសឹសនឹងត្រូវគេយកមកដាក់ផ្ទះអ្នកជាច្រើនថ្ងៃមុនពេលធ្វើសិនសឹសថ្ងៃទី៦មិនា២០០១។ ធ្វើដូច្នេះគឺដើម្បីឲ្យអ្នកមានពេលមើលសន្លឹកនោះឲ្យយល់ពីសំនួរដែលគេសួរ។ មានគេដើរប្រមូលយកសន្លឹកទាំងនោះវិញ២ឬ៣ថ្ងៃក្រោយពីថ្ងៃសិនសឹស។

អ្នកដែលដើរចែកនិងប្រមូលសន្លឹកសិនសឹសគេហៅថាអេនូមេរិយេធរ (Enumerator)។ គាត់មានស្បោងពិតខៀវមួយដើម្បីចំណាំ ហើយមានខ្ទាស់សញ្ញាសំគាល់ខ្លួនខាងក្រសួងស្ថិតិញូស៊ីឡែនដោយមានបិតរូបថតនៅលើនោះទៀត។